## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

លេខ ០៩៥ ពម.ប្រក

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែជេស្ឋ... ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី.១៤.. ខែមិថុនា........ ឆ្នាំ២០២២.

## ប្រកាស
## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស.រ.ក.ម០៨៩៥០៧ ចុះថ្ងៃទី០១ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខនសរកម០១៩៦១២ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០អនក្រ.បក ចុះថ្ងៃទី០៥ខែសីហាឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល និងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍
- បានឃើញប្រកាសលេខ ៦២៣ ព.ម ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ក្រសួងព័ត៌មាន
- យោងតាមស្ថានភាពជាក់ស្ដែង

## សម្រេច

**ប្រការ១._**

ត្រូវលុបប្រកាសលេខ ៦២៣ ព.ម ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ក្រសួងព័ត៌មាន ដែលអនុញ្ញាតឱ្យលោក ជា សារ៉េន កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ ០៩០៥៦០៧៥៦ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣ មានអាសយដ្ឋាននៅភូមិព្រៃចារ ឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ជាម្ចាស់សហគ្រាសកាសែត ដំណឹងក្នុងស្រុក ធ្វើអាជីវកម្មផ្សព្វផ្សាយតាមកាសែត មានអាសយដ្ឋានទីស្នាក់ការស្ថិតនៅផ្ទះលេខEA ៧០២៩ ផ្លូវលំ ក្រុម៣ ភូមិត្នោត សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដោយមូលហេតុ ម្ចាស់អាជ្ញាបណ្ណបានប្រព្រឹត្តិកំហុសខាងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានយ៉ាងធ្ងន់ធ្ងរ និងមិនព្រមអនុវត្តតាមការអប់រំណែនាំរបស់ក្រសួងជាអាណាព្យាបាល ដែលផ្ទុយនឹងកិច្ចសន្យាអាជីវកម្មរបស់សាមីខ្លួនបានតម្កល់ទុកនៅក្រសួងព័ត៌មាន ។

**ប្រការ២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៣._**

អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកខុទ្ទកាល័យក្រសួងព័ត៌មាន ប្រធានមន្ទីរព័ត៌មានរាជធានី ខេត្ត សាមីខ្លួន និងសមត្ថកិច្ចពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ខៀវ កាញារីទ្ធ

កន្លែងទទួល:
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- សាលារាជធានី ខេត្ត
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Building62, Monivong BLVD,Sangkat Srah Chork, Khan Daun Penh, PhnomPenh E-mail:information@info.gov.kh